# តើអ្វីខ្លះដែលស្ត្រីត្រូវដឹងអំពីការវះកាត់ស្បូនម្យ៉ាងហៅ “ហ៊ីសថិរិចថូមី”

# What women should know about hysterectomy

រៀងរាល់ឆ្នាំក្នុងប្រទេសអូស្ត្រាលី មានស្ត្រីជាច្រើនរាប់ពាន់នាក់ដែលដឹងថា ខ្លួនត្រូវការការវះកាត់ស្បូនម្យ៉ាងហៅ “ហ៊ីសថិរិចថូមី”(hysterectomy) - នេះគឺជាការវះកាត់យកស្បូន(uterus ឬ womb)ចេញ។ ក៏ប៉ុន្តែទោះបីនេះជាការវះកាត់ធម្មតាមួយសំរាប់ព្យាបាលបញ្ហាមួយចំនួនក្តី គេច្រើនតែមានការភ័ន្តច្រឡំអំពីការវះកាត់ស្បូននេះ។

<u>តើមូលហេតុអ្វីបានជាស្ត្រីត្រូវការការវះកាត់នេះ</u> ?

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយពេលដែលស្ត្រីជិតចូលដល់វ័យឈប់មានរដូវ(Menopause) ស្ត្រីខ្លះមានធ្លាក់ឈាមច្រើនពីទ្វារមាស(យោនី) ហើយដែលច្រើនតែមិនអាចដឹងជាមុនផង។ បុព្វហេតុនេះបណ្តាលមកពីមានការផ្លាស់ប្តូរខាងជាតិអ័រមូន(hormone) ឬដោយសារជាតិម្យ៉ាងហៅ Fibroids (ជាជាតិម្យ៉ាងដែលករកើតនៅក្នុងស្បូន តែមិនមែនជាមហារីកទេ)។ ទោះបីជាតិ Fibroids នេះ ច្រើនតែមិនបណ្តាលឲ្យមានបញ្ហាក្តី តែជួនកាលវាអាចបណ្តាលឲ្យធ្លាក់ឈាមច្រើន ព្រមជាមួយនិងបញ្ហាផ្សេងៗទៀត។ បុព្វហេតុផ្សេងទៀតទោះបីមិនសូវមានក្តី ដែលតម្រូវឲ្យមានការវះកាត់ស្បូននេះ មានដូចជាជម្ងឺមហារីកស្បូន, មហារីកអណ្ឌាស័យ(កដៃស្បូនទាំង២)(Ovaries) និងមហារីកកស្បូន (Cervix)។

<u>តើការវះកាត់ស្បូនហៅ “ហ៊ីសថិរិចថូមី”នេះ មានត្រូវយកអណ្ឌាស័យចេញដែរឬទេ</u> ?

មិនចាំបាច់យកអណ្ឌាស័យចេញគ្រប់ការវះកាត់នោះទេ។ គេត្រូវយកអណ្ឌាស័យចេញតែខណៈណាដែលមានជម្ងឺនៅអណ្ឌាស័យប៉ុណ្ណោះ ឬប្រសិនបើស្ត្រីទទួលការវះកាត់នោះចូលដល់វ័យឈប់មានរដូវទៀត។ ការវះកាត់យកអណ្ឌាស័យទាំង២ចេញពេលវ័យឈប់មានរដូវ ការពារមិនឲ្យមានជម្ងឺមហារីកអណ្ឌាស័យទៅពេលអនាគត។ ចំពោះស្ត្រីដែលមិនទាន់ដល់វ័យឈប់មានរដូវ ការវះកាត់យកអណ្ឌាស័យចេញបណ្តាលឲ្យឈប់មានរដូវភ្លាមតែម្តង។ ចំពោះស្ត្រីវ័យក្មេងណាដែលវះយកអណ្ឌាស័យចេញមុនវ័យឈប់មានរដូវ ត្រូវពិគ្រោះជាមួយវេជ្ជបណ្ឌិតអំពីការព្យាបាលប្រើជាតិអ័រមូនជំនួស(hormone replacement therapy)។

<u>តើមានតែការព្យាបាលដោយការវះកាត់ស្បូនហៅ “ហ៊ីសថិរិចថូមី”នេះ ឬដូចម្តេច</u> ?

ទោះបីការវះកាត់ស្បូននេះជាការចាំបាច់ចំពោះជម្ងឺមហារីកខ្លះក្តី តាមធម្មតាវាជាមធ្យោបាយចុងក្រោយបំផុតចំពោះបញ្ហានៃការធ្លាក់ឈាមច្រើន ឬបញ្ហាបណ្តាលមកពីជាតិ Fibroids។ ចូរពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកពីវិធីព្យាបាលផ្សេងៗទៀត មានដូចជាការយកជាតិ Fibroidsចេញ ការបន្ថយឬការការពារកុំឲ្យធ្លាក់ឈាមដោយការប្រើជាតិអ័រមូនសំរាប់ព្យាបាល ឬការព្យាបាលសំរាប់យកស្រទាប់ស្បូន (lining of the uterus)ចេញ។

តើការវះកាត់ស្បូន“ស៊ីសថីរិចថូមី៊”នេះ ធ្វើតាមរបៀបណា ?

បច្ចេកទេសនៃការវះកាត់ស្បូន”ហ៊ីសថីរិចថូមី៊”មានច្រើនយ៉ាង ហើយដែលមានសារប្រយោជន៍និងការពិបាកផ្សេងៗគ្នា។ វេជ្ជបណ្ឌិតរបស់អ្នកអាចពិគ្រោះចំណុចទាំងនេះជាមួយអ្នក។

- ការវះកាត់“ហ៊ីសថីរិចថូមី៊”តាមពោះ(Abdominal hysterectomy) – នេះជាការវះកាត់យកស្បូនចេញដោយវះកាត់បណ្តោយពោះជិតថ្ងាស។ ការវះកាត់នេះតែងតែធ្វើនៅម្តុំពោះ ហើយទាក់ទងនិងការវះយកអណ្ឌាស័យនិងកស្បូនចេញ។ ការវះកាត់តិចជាងនេះដែលគេហៅថា "subtotal" hysterectomy គឺគេទុកកស្បូននៅដដែល។
- ការវះកាត់ស្បូនតាមទ្វារមាស(Vaginal hysterectomy) – នេះគឺជាការវះកាត់យកស្បូនចេញដោយវះតាមទ្វារមាស(យោនី)។ ការវះកាត់របៀបនេះមិនទុកឲ្យឃើញមានស្លាកស្នាមទេ។

តើការវះកាត់ស្បូន“ហ៊ីសថីរិចថូមី៊”មានឥទ្ធិពលដូចម្តេចខ្លះ ?

ការវះយកស្បូនចេញមានន័យថា ការមានរដូវក៏ឈប់លែងមានទៀត ហើយក៏មិនអាចមានផ្ទៃពោះទៀតដែរ។ វាជាការមិនពិតទេដែលថាការវះកាត់“ហ៊ីសថីរិចថូមី៊” បណ្តាលឲ្យឡើងទម្ងន់ ឬមានការផ្លាស់ប្តូរបុគ្គលិកលក្ខណៈ។ យ៉ាងណាក្តីស្ត្រីខ្លះ ជាពិសេសស្ត្រីវ័យក្មេង អាចមានអារម្មណ៍រកាំចិត្តពីការដែលមិនអាចមានកូនទៀត។ ម្យ៉ាងទៀតវាជាការធម្មតាចំពោះជនខ្លះដែលអាចមានអារម្មណ៍មិនសប្បាយក្រោយពីការវះកាត់ធំដុំណាមួយ។ ស្ត្រីជាច្រើនយល់ថាមានសារប្រយោជន៍ដោយពិគ្រោះនូវការព្រួយចិត្តនេះជាមួយវេជ្ជបណ្ឌិតដែលធ្វើការវះកាត់ ឬជាមួយវេជ្ជបណ្ឌិតផ្ទាល់របស់អ្នក។ អ្នកក៏អាចទៅមណ្ឌលសុខភាពស្ត្រី(Women’s health centre), សមាគមគម្រោងការគ្រួសារ(Family Planning Association), មន្ទីរពិនិត្យសុខភាព ឬមណ្ឌលសុខភាពសហគមន៍(Community health centre)។

តើអស់រយៈពេលប៉ុន្មានទើបជាសះស្បើយក្រោយពីការវះកាត់ ?

ការវះកាត់“ហ៊ីសថីរិចថូមី៊”តាមពោះ(Abdominal hysterectomy) ត្រូវនៅគេងពេទ្យប្រហែល៥ថ្ងៃ ហើយប្រហែលត្រូវការពេលពី៦ទៅ៨អាទិត្យដើម្បីឲ្យជាសះស្បើយ។ ការវះកាត់ស្បូនតាមទ្វារមាស (Vaginal hysterectomy)ត្រូវគេងនៅមន្ទីរពេទ្យប្រហែល២ថ្ងៃ ហើយអាចត្រូវការពេលដល់៤អាទិត្យដើម្បីឲ្យជាសះស្បើយ។

តើអស់រយៈពេលប៉ុន្មានទើបអាចរួមសង្វាសបានវិញ ?

ប្រហែល៦ទៅ៨អាទិត្យ។ ការវះកាត់យកស្បូនចេញ“ហ៊ីសថីរិចថូមី៊” មិនមានឥទ្ធិពលដល់កាមតណ្ហា ឬភាពសម្រើបបំផុតរបស់ស្ត្រីទេ។ ស្ត្រីដែលមានបញ្ហាធ្លាក់ឈាមច្រើន ឬមានការពិបាកពេលរួមសង្វាសមុនពេលវះកាត់ អាចបានស្រួលសប្បាយឡើងក្រោយពីការវះកាត់។

តើការធ្វើ“ផាបតេស្ត“(**Pap test**)យ៉ាងដូចម្តេចដែរ ក្រោយពីការះកាត់ស្បូន“ហ៊ីសថីរិចថូមី៊” ?

ចំពោះស្ត្រីដែលមិនមានវះយកកស្បូន(Cervix)ចេញ ស្ត្រីនោះត្រូវធ្វើ“ផាបតេស្ត”ជារឿយៗពីរឆ្នាំម្តង ឬតាមឪវាទពីវេជ្ជបណ្ឌិត។ ស្ត្រីនោះក៏ត្រូវទៅជួបវេជ្ជបណ្ឌិតដែរបើកាលណាមានធ្លាក់ឈាម។


Website: http://www.mhcs.health.nsw.gov.au
e-mail: mhcs@sesiahs.health.nsw.gov.au
phone: (02) 9816 0347

លេខទូរស័ព្ទទាំងនេះត្រឹមត្រូវនៅពេលបោះពុម្ពក៏ប៉ុន្តែអាចមិនបានកែតម្រូវតាមការលៈទេសៈ។ លោក-ស្នា ប្រហែ អាចត្រូវមើលបញ្ជាក់លេខនៅក្នុង“សៀវភៅទូរស័ព្ទ” (Telephone Directory)។

ចំពោះពត៌មានបន្ថែមទៀតស្តីអំពីការវះកាត់ស្បូន”ហ៊ីសថឺរិចថូមី” ចូរពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នក ឬមណ្ឌលសុខភាពស្ត្រី (Women’s health centre)។

ប្រសិនបើអ្នកមានការពិបាកក្នុងការទូរស័ព្ទជាភាសាអង់គ្លេស សុំអ្នកទាក់ទងទៅផ្នែកផ្តល់អ្នកបកប្រែ Translating and Interpreting Service (អក្សរកាត់ **TIS**) លេខ 131 450។

អ្នកអាចយកពត៌មានផ្នែកសុខភាពបន្ថែមទៀតជាភាសាខ្មែរ ពីកំព្យូទ័រតាមរយៈ **Multicultural Communication website at** http://www.mhcs.health.nsw.gov.au